អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# យើងអាច គ្រាន់តែតាមវិធីផ្សេងគ្នា

## We Can - Just Differently



សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by TukTuk

Illustrated by Choven Hen

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




យ៉េកសួរ « នៅថ្ងៃឈប់សម្រាក តើអ្នកទៅដើរលេងនៅភ្នំពេញសប្បាយទេ? »
រតនាឆ្លើយ « ចាស! សប្បាយខ្លាំងណាស់! ទោះបីជាពួកយើងត្រូវទៅសាលាជាមួយមីង
របស់ពួកយើងក៏ដោយ »។



យ៉េកសួរទាំងឆ្ងល់ « អ្នកត្រូវទៅសាលាក្នុងថ្ងៃឈប់សម្រាកទៀត? ធ្វើអីចឹង មិនសប្បាយទេមើលទៅ! »
« អូ! សប្បាយទេតើ! អ្នកមីងដារិនធ្វើការនៅឯសាលាសម្រាប់ក្មេងដែលត្រូវការការអប់រំពិសេស។
នៅទីនោះ ពួកយើងបានស្គាល់មិត្តភក្តិល្អៗជាច្រើន »។



មករានិយាយ « នៅម៉ោងសិល្បៈ ខ្ញុំបានអង្គុយជិតក្មេងប្រុសម្នាក់ឈ្មោះទី។
គាត់កើតមក ដោយពិការដៃទាំងសងខាង »។យ៉េកក៏សួរ « ម៉ោងសិល្បៈ? តើគាត់គូររូបយ៉ាងណាទៅ បើពិការដៃ? »
« គាត់អាចគូរបានទេតើ! គ្រាន់តែតាមវិធីផ្សេងពីយើង។ គាត់ប្រើមាត់ដើម្បីគូររូប »។
យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



« នៅល្ងាចនោះ ខ្ញុំនិងរតនាបានសាកល្បងធ្វើដូចគាត់ដែរ ប៉ុន្តែយើងបានធ្វើឱ្យថ្នាំពណ៌ប្រឡាក់គ្រប់ទីកន្លែង »។



រតនានិយាយ « ខ្ញុំបានជួបក្មេងស្រីម្នាក់ឈ្មោះចិន្តាដែលនាងពិការភ្នែក។ កាលនោះ នាងកំពុងអានសៀវភៅ »។
យ៉េកសួរ « អានសៀវភៅ? តើនាងអានសៀវភៅយ៉ាងណាទៅ បើនាងពិការភ្នែក? »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




រតនាក៏បកស្រាយ « នាងអាចអានបានតើ គ្រាន់តែតាមវិធីផ្សេងពីយើង។ សៀវភៅរបស់នាង គឺសរសេរឡើងដោយប្រើអក្សរស្ទាប។ តួអក្សរនីមួយៗផុសឡើងមក ហើយនាងអានដោយប្រើម្រាមដៃរបស់នាង »។ យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



« មានក្មេងខ្លះដែលជិះរទេះ បានហៅពួកយើងឱ្យលេងបាល់បោះជាមួយពួកគាត់ »។
យ៉េកសួរ « បាល់បោះ! តើពួកគាត់អាចលេងបាល់បោះតាមរបៀបណាទៅ? »
« តើអ្នកទាំងពីរ ត្រូវជិះរទេះដូចពួកគាត់ដែរឬទេ? »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



« ពួកគាត់អាចលេងបានទេតើ គ្រាន់តែតាមវិធីផ្សេងពីយើង។ ពួកយើងរត់ ឯពួកគាត់វិញ បង្វិលកង់រទេះ។ ពួកគាត់បោះចូលសឹងតែរាល់ដង! »

យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



« ពួកយើងបានជួបក្មេងប្រុសម្នាក់ឈ្មោះមេសាដែលពិការត្រចៀក។ ពួកយើងបានលេងល្បែងតាថាជាមួយគ្នា »។
យ៉េកសួរ « ល្បែងតាថា! តើធ្វើយ៉ាងណាទើបគាត់ដឹងថាខ្លួនត្រូវធ្វើអ្វី បើគាត់ស្ដាប់មិនឮផងហ្នឹង? »
« គាត់អាចស្ដាប់ឮបាន គ្រាន់តែតាមវិធីផ្សេងពីយើង។ គាត់ឈរនៅខាងមុខ ដូច្នេះគាត់អាចមើលមាត់របស់អ្នកគ្រូ ធ្វើយ៉ាងនេះគាត់អាច “ស្ដាប់” អ្នកគ្រូយល់បាន »។



« ដំបូង មីងដារីននិយាយដោយសំឡេងធម្មតា យើងទាំងអស់គ្នាអាចធ្វើបាន។
តែក្រោយមក គាត់ខ្សឹបដោយមិនបញ្ចេញសំឡេងទេ។
ពេលនោះយើងមិនអាចស្ដាប់គាត់ឮ ហើយក៏មិនដឹងថាត្រូវធ្វើអ្វីដែរ មានតែមេសាទេដែលដឹងនិងយល់ »។
យ៉េកនិយាយ « អូ! អស្ចារ្យណាស់! »



នៅយប់នោះ រតនាបានគិតដល់សំណាងដែលទើបប្តូរចូលថ្នាក់របស់នាង។ គាត់មានជំងឺអូទីសឹម។
គាត់មិនចូលចិត្តលេងល្បែងទេ ហើយក៏មិននិយាយច្រើនដែរ។ ក្មេងដទៃទៀតនៅក្នុងថ្នាក់គិតថាគាត់ជាក្មេងចម្លែក។
រតនាគិតថា « ប្រហែលជា សំណាងដូចជាក្មេងៗនៅសាលារបស់មីងដារិនអ៊ីចឹង។
គាត់អាច គ្រាន់តែតាមវិធីផ្សេង »។





នៅថ្ងៃបន្ទាប់ រតនាបានសួរសំណាង «តើអ្នកចាប់អារម្មណ៍លើរឿងអ្វី?»
សំណាងឆ្លើយ « លំហ » ។
បន្ទាប់មក គាត់ក៏ចាប់ផ្តើមប្រាប់រតនាពីរឿងរ៉ាវជាច្រើនដែលទាក់ទងនឹងភពនិងអវកាសយានិក។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ក្មេងដទៃក៏ចាប់ផ្តើមចូលរួមស្តាប់ផងដែរ។

ក្មេងម្នាក់បាននិយាយ « អូ! អស្ចារ្យណាស់! អ្នកដឹងពីរឿងលំហច្រើនមែនទែន!
តើអ្នកចង់លេងល្បែងអវកាសយានិកនិងមនុស្សភពផ្សេងដែរឬទេ? »

«បាទ ចង់តើ» សំណាងឆ្លើយ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




សំណាងលេងរហូតដល់ឮសំឡេងជួង។ ពេលដែលពួកគាត់កំពុងដើរទៅថ្នាក់រៀនវិញ រតនាបានឮមិត្តរួមថ្នាក់ពីរនាក់និយាយគ្នា។ ម្នាក់និយាយ « តាមពិតគាត់មិនសូវដាចម្លែកប៉ុន្មានទេ »។ ម្នាក់ទៀតក៏បន្តឆ្លើយ៖ « មែនហើយៗ! គ្រាន់តែគាត់មានវិធីផ្សេងពីយើង »។ រតនានិងមករាក៏និយាយទៅកាន់អ្នកទាំងអស់គ្នា « អូ! អស្ចារ្យណាស់ៗ! »៕